# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

*ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

*ក្រសួងពាណិជ្ជកម្ម*

*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ*

*ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល*

*លេខ : ៤០១ សហវ.ប្រក*

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការពង្រឹងការត្រួតពិនិត្យទំនិញដែលជា ម្ហូបអាហារ រុក្ខជាតិ ផលិតផលរុក្ខជាតិ សត្វ ផលិតផលពីសត្វ ជលផល និង ផលិតផលជលផល ដែលគ្មានសុវត្ថិភាព នាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា

- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

- យោងប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម លេខ ៩៩៤ សហវ.ប្រក ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល លេខ ៩៩៥ សហវ.ប្រក ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ ៥១៥/៤៣៧ សហវ.ប្រក.កសក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១០ ស្តីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងប្រកាសអន្តរក្រសួងលេខ ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០ ស្តីពីការអនុវត្ត និងការរៀបចំសម្របសម្រួលស្ថាប័នកិច្ច នៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ចាប់ពីកសិដ្ឋានផលិត ដល់តុបរិភោគ
- ដោយសង្កេតឃើញថា ទំនិញនាំចូលមួយចំនួន ដូចជា សត្វរស់ សាច់ស្រស់ សាច់ក្រៀមគ្រប់ប្រភេទ បន្លែ ផ្លែឈើ ផ្កាស្រស់ ផ្កាក្រៀម ជលផល និងផលិតផលកែច្នៃភាគច្រើនជាទំនិញខូចគុណភាព ផ្ទុកដោយសារធាតុគីមីគ្រោះថ្នាក់ ខុសលក្ខណៈបច្ចេកទេស និងមានផ្ទុកមេរោគ ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ រុក្ខជាតិ និងបរិស្ថាន នៅកម្ពុជា
- យោងចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ លើលិខិតលេខ ២៩៣៨ សហវ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណង :

- ពង្រឹងការអនុវត្តលិខិតបទដ្ឋានច្បាប់ជាធរមាន ក្នុងគោលបំណងទប់ស្កាត់ការនាំចូលនូវម្ហូបអាហារ រុក្ខជាតិ ផលិតផលរុក្ខជាតិ សត្វ ផលិតផលមានដើមកំណើតពីសត្វ ជលផល និងផលិតផលជលផល ដែលគ្មានសុវត្ថិភាព បង្កឱ្យមានផលប៉ះពាល់ដល់សុខភាពមនុស្ស សត្វ រុក្ខជាតិ និងបរិស្ថាន។
- រក្សា និងបង្កើនលំហូរពាណិជ្ជកម្មអន្តរជាតិ ដោយធ្វើយ៉ាងណាឱ្យការធ្វើពាណិជ្ជកម្មស្របតាមច្បាប់ជាតិ កិច្ចព្រមព្រៀងតំបន់ និងកិច្ចព្រមព្រៀងអន្តរជាតិនានា។